ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ......០៥៤.......បទ..........................

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥

# សាររំលែកមរណទុក្ខ

**សូមគោរពជូន**
**ឯកឧត្តម សាយ ឈុំ ប្រធានស្តីទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ថ្នាក់នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមចូលរួមមរណទុក្ខយ៉ាងសែនក្រៀមក្រំបំផុត និងសោកស្តាយអាឡោះអាល័យក្រៃលែង ដោយ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជាបានទទួលមរណភាពនៅថ្ងៃច័ន្ទ ៧រោច ខែជេស្ឋ ឆ្នាំមមែ សប្តស័ក ព.ស២៥៥៩ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ វេលាម៉ោង ១៥:៤៥នាទី ក្នុងជន្មាយុ ៨៣ឆ្នាំ ដោយរោគាពាធ។

យើងខ្ញុំទាំងអស់គ្នា ដែលកំពុងសោកស្តាយអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបាននោះ សូមគោរពសម្តែងនូវកតញ្ញូកតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ជូនចំពោះសម្តេច ដែលជាឥស្សរជននយោបាយជាន់ខ្ពស់មួយរូប និងបានចូលរួមដឹកនាំចលនាតស៊ូប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយនាំមកនូវសុខសន្តិភាព ឯកភាពជាតិ ការអភិវឌ្ឍ និងកិត្យានុភាពជាតិ ទាំងនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។

ក្នុងឱកាសដ៏មហាសែនក្រៀមក្រំនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ថ្នាក់នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមលំឱនកាយវាចាចិត្តចូលរួមរំលែកនូវមរណទុក្ខដោយក្តីសោកសង្រេងបំផុត ជាមួយឯកឧត្តមប្រធានស្តីទី ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណមបួងសួង សូមឲ្យវិញ្ញាណក្ខន្ធរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** បានយោនយកកំណើតក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**
**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

ប្រាក់_សុខុន